ព្រះគម្ពីរសំរាប់កុមារ
សូមបង្ហាញជូន

# ព្រះអម្ចាស់ដែល
# គេស្រង់ចេញពី
# ទឹកទន្លេ



និពន្ធដោយ៖ Edward Hughes

ធ្វើការពន្យល់ដោយ៖ M. Maillot; Lazarus
Alastair Paterson

កែសម្រួលដោយ៖ M. Maillot; Sarah S.

បកប្រែដោយ៖ www.christian-translation.com

ផលិតដោយ៖ Bible for Children
www.M1914.org

©2023 Bible for Children, Inc.
អាជ្ញាប័ណ្ណ៖ លោកអ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន
តែលោកអ្នកមិនអាចយកវាទៅលក់បានទេ។

លោកនាយករដ្ឋមន្ត្រី យ៉ូសែប បាន
ទទួលមរណៈ។ ជនជាតិអេស៊ីបទាំង
អស់បានចូលរួមមរណៈទុក្ខជាមួយ
គ្រួសាររបស់ លោក។



ព្រះជាម្ចាស់បានប្រើលោកយ៉ូសែប
ជាជនជាតិហេប្រឺដើម្បីសង្គ្រោះ
ប្រទេសឲ្យរួចផុតពីគ្រោះអត់ឃ្លាន។
លោកជាអ្នក ដឹកនាំដែលឆ្លៀសវៃ
និង គួរឲ្យស្រឡាញ់។ ពេលនេះ

លោកបានលាទៅដោយ
មិនត្រឡប់វិញ។



ជាងបីរយឆ្នាំកន្លងផុតទៅយ៉ាងរហ័ស។ ប្រជាជនរបស់លោកយ៉ូសែប គឺជនជាតិហេប្រឺ បានក្លាយជាជនជាតិដ៏ខ្លាំងពូកែមួយក្នុងប្រទេសអេស៊ីប។ ព្រះចៅផារ៉ោនដែលសោយរាជ្យថ្មី មិនស្គាល់លោកយ៉ូសែបទេ ព្រះអង្គខ្លាចជនជាតិហេប្រឺបះបោរប្រឆាំងនឹងទ្រង់ ដូច្នេះហើយទ្រង់បានបង្ខំគេឲ្យធ្វើជាទាសករ។



ព្រះចៅផារ៉ោន បានប្រព្រឹត្តចំពោះជនជាតិហេប្រឺយ៉ាងឃោរឃៅបំផុត។ ព្រះអង្គបានបង្ខំពួកគេឲ្យសង់ទីក្រុងធំៗជាច្រើន។ ប៉ុន្តែការងារកាន់តែលំបាកយ៉ាងណា ទាសករជាតិហេប្រឺកាន់តែកើនចំនួនច្រើនឡើងជានិច្ច។



ថ្ងៃមួយនោះ ព្រះចៅផារ៉ោន បានចេញរាជបញ្ជាដ៏គួរឲ្យខ្លាចមួយ។ រាជ
បញ្ជារមានសេចក្តីដូច្នេះថា ៖ “ត្រូវយកទារកភេទ ប្រុសដែលជាកូនរបស់
ជនជាតិហេប្រើទាំងអស់ទៅបោះចោលក្នុងទឹកទន្លេនីល”។ ព្រះចៅផារ៉ោ
នជាស្តេចដ៏អាក្រក់នេះ បានប្តេជ្ញាកាត់បន្ថយចំនួនជនជាតិហេប្រើឲ្យនៅ
តិច។ សូម្បីតែទារកដែលទើបនឹងកើតក៏
ស្តេចអង្គនេះ សម្លាប់ដែរ។



មានគ្រួសារមួយនៃជនជាតិហេប្រឺបានទាំងងឿងឆ្ងល់ថា ៖ “តើយើងអាចធ្វើអ្វីបានខ្លះទេ?” ពួកគេក៏បានសម្រេចចិត្ត យកកូនប្រុសរបស់គេទៅដាក់នៅក្នុងទន្លេនីល។ ប៉ុន្តែគេបានដាក់កូននៅក្នុងជាលដ៏កក់ក្ដៅមួយដែលមិនជ្រាបទឹក។



ជាលដ៏តូចនោះបានអណ្តែតនាំយកអ្នកដំណើរដ៏មានតម្លៃរបស់វានៅក្បែរគុម្ពត្រែង។ តើនឹងមានអ្វីកើតឡើងចំពោះទារកដ៏តូចដែលនៅក្នុងជាលនោះ?



បងស្រីរបស់ទារកនោះ តាមមើលជាលដែលអណ្ដែតនោះពីចម្ងាយ
ខណៈវាកំពុងអណ្ដែតនាំយកទារកយកទៅក្បែរគុម្ពត្រែង។



រំពេចនោះ បុត្រីរបស់ព្រះចៅផារ៉ោន និង ស្រីស្នំ
បានយាងមកស្រង់ទឹកទន្លេ។ គុម្ពព្រែងមិនអាច
លាក់ជាលនោះ ពីព្រះនាងបានឡើយ។ ប្រហែល
គេដើរកាត់តាមនោះដោយមិនចាប់អារម្មណ៍។



“អូហ៍! មានជាលមួយ។ នៅត្រង់គុម្ពព្រែងនោះ។ ខ្ញុំចង់ដឹងណាស់ថាមានអ្វីនៅក្នុងជាលនោះ”។ បុត្រីរបស់ព្រះចៅផារ៉ោនបញ្ជារឲ្យស្នំរបស់ព្រះនាងស្រង់យកជាលនោះឡើងលើគោក។ ព្រះនាងបានបើកជាលនោះមើល ស្រាប់តែព្រះនាងទតឃើញទារកម្នាក់ ហើយរកដែលនៅក្នុង ជាលនោះ ស្រែកយំឡើង។ ព្រះនាងមានបន្ទូលថា ៖ “ទារកនេះ គឺពិតជាកូនរបស់ជនជាតិហេប្រឺហើយ!”។



“ទារកដ៏កំសត់អើយ! ឯងស្អាតណាស់”។ ប្រហែលបុត្រីរបស់ព្រះចៅផា
រ៉ោននិយាយទៅកាន់ទារកនោះ ដូចជាមនុស្ស ផ្សេងទៀតនិយាយពេល
គេឃើញទារកដែរ។ ព្រះនាងអាចមានព្រះ
បន្ទូលជាភាសាអេស៊ីបថា ៖
“គូឈី-កូឈី គូ-អ៊ុំ”។



ព្រះជាម្ចាស់បានប្រទានប្រាជ្ញាយ៉ាងពិសេសដល់បងស្រីរបស់ទារក
នោះ។ នាងតូចបានរត់ទៅរកបុត្រីព្រះចៅផារ៉ោនហើយទូលថា ៖ “តើ
ព្រះនាងសព្វព្រះហឫទ័យឲ្យ ខ្ញុំម្ចាស់ទៅរកស្ត្រីមេដោះជាតិហេប្រឺឲ្យ
មើលថែទាំទារកនេះជំនួសព្រះនាងឬទេ ក្រាបទូល?”។
ព្រះនាងមានព្រះបន្ទូលថា ៖ “ចូរទៅចុះ!”។
តើប្អូនៗយល់ថា នាងតូចនោះនឹងរត់ទៅ
រកនរណាឲ្យធ្វើជាមេដោះ?



នាងតូចនោះបានរត់ទៅរកម្ដាយហើយប្រាប់ថា ៖ “ម៉ែ! មកឲ្យលឿនឡើង! ប្រញាប់ឡើង!”។ ប្រហែលនាងតូចនោះ គ្មានពេលដើម្បីនឹងពន្យល់ម្ដាយរបស់នាងឡើយ។

ទាំងម្ដាយទាំងកូនស្រីបានរត់ចុះទៅឯកំពង់ទឹក។



គឺចុះទៅឯមាត់ទន្លេ បុត្រីព្រះចៅផារ៉ោនប្រគល់ទារកនោះឲ្យនាង ហើយមានបន្ទូលថា ៖ “ចូរយកទារកនេះទៅបំបៅឲ្យខ្ញុំ ផង។ ខ្ញុំនឹងឲ្យប្រាក់ឈ្នួលដល់អ្នក។ ខ្ញុំដាក់ឈ្មោះទារកនេះថា ម៉ូសេ”។ ពាក្យអេស៊ីបថា “ម៉ូសេ” មានន័យថា “ស្រង់ចេញពីទឹក”។



ទារកម៉ូសេ ត្រូវបានត្រឡប់ទៅឯឪពុកម្តាយ និង
គ្រួសាររបស់ខ្លួនវិញ។ ពួកគេបានបង្រៀនគាត់ឲ្យ
ស្រឡាញ់ព្រះជាម្ចាស់ និង ស្រឡាញ់ជនជាតិហេ
ប្រឺ។ លោកនឹងរស់នៅក្នុងរាជវាំងជាមួយបុត្រីព្រះ
ចៅផារ៉ោនក្នុងពេល
ដ៏ឆាប់នេះ។
ព្រះជាម្ចាស់
បានសង្គ្រោះជីវិតគាត់
គឺទ្រង់មានផែនការ
ដ៏អស្ចារ្យសម្រាប់គាត់
នាពេលអនាគត។





ព្រះអម្ចាស់ដែលគេស្រង់ចេញពីទឹកទន្លេ

រឿងមួយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់,

អាចរកឃើញនៅក្នុងព្រះគម្ពីរ

និក្ខមនំ ២

“ការស្វែងយល់ព្រះបន្ទូលរបស់ព្រះអង្គ ធ្វើឲ្យមនុស្សភ្លឺស្វាង
ហើយធ្វើឲ្យអ្នកទន់ទាបមានប្រាជ្ញា។”
ទំនុកតម្កើង 119:130

ចប់

រឿងព្រះគម្ពីរនេះប្រាប់យើងពីព្រះជាម្ចាស់ដ៏អស្ចារ្យរបស់យើងដែលបានបង្កើតយើងមក ហើយចង់អោយអ្នកស្គាល់ទ្រង់។

ព្រះអង្គជ្រាបថា យើងបានប្រព្រឹត្តអំពើអាក្រក់, ដែលទ្រង់ហៅការទាំងនោះថាជា អំពើបាប។ ទោសនៃអំពើបាបគឺសេចក្តីស្លាប់, ប៉ុន្តែព្រះទ្រង់ស្រឡាញ់យើងខ្លាំងណាស់ ដល់ម៉្លេះហើយបានជាទ្រង់បានចាត់ព្រះយេស៊ូដែលជាព្រះរាជបុត្រាតែមួយរបស់ព្រះអង្គអោយមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោសនោះជំនួសយើង។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រលប់ទៅស្ថានសួគ៌! ប្រសិនបើអ្នកជឿលើព្រះយេស៊ូ ហើយសុំទ្រង់អោយអភ័យទោសចំពោះអំពើបាបរបស់អ្នក, ទ្រង់នឹងលើកលែងទោសអោយអ្នក! ទ្រង់នឹងមក ហើយរស់ក្នុងចិត្តរបស់អ្នកឥឡូវនេះ, ហើយអ្នកនឹងរស់នៅជាមួយទ្រង់ជារៀងរហូត។

ប្រសិនបើអ្នកជឿថានេះជាការពិត, អ្នកត្រូវទូលទៅកាន់ព្រះអង្គថា៖ ឱព្រះយេស៊ូទូលបង្គំជឿហើយថាទ្រង់ជាព្រះ ហើយបានក្លាយជាមនុស្សម្នាក់មកដើម្បីសុគតជំនួសអំពើបាបរបស់ទូលបង្គំ, ហើយពេលនេះទ្រង់រស់ពីសុគតឡើងវិញ។ សូមទ្រង់យាងចូលក្នុងជីវិតរបស់ទូលបង្គំ ហើយអភ័យទោសចំពោះអំពើបាបរបស់ទូលបង្គំ ដើម្បីទូលបង្គំអាចមានជីវិតថ្មីនាពេលឥឡូវនេះបាន ហើយថ្ងៃមួយទូលបង្គំនឹងទៅនៅជាមួយទ្រង់ជារៀងរហូត។ សូមជួយទូលបង្គំអោយគោរពទ្រង់ហើយរស់នៅសំរាប់ទ្រង់ដូចជាបុត្ររបស់ទ្រង់។ អាម៉ែន។

សូមអានព្រះគម្ពីរ ហើយអធិដ្ឋានទៅព្រះជារៀងរាល់ថ្ងៃ! យ៉ូហាន ៣:១៦